ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៣៩៤ ប្រក.កសក

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការគ្រប់គ្រងបសុឱសថ និងវត្ថុធាតុជីវៈបសុព្យាបាល ដែលធ្វើពាណិជ្ជកម្ម និងធ្វើការលាយផ្សំ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយក-ដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្ដីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.កប ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្ដីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.កប ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.កប ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- បានឃើញប្រកាសរួមលេខ១០១៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ២០៨ ប្រក.កសក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ ស្ដីពីនីតិវិធី និងការតម្រូវបមាណីយសម្រាប់ចុះបញ្ជីបសុឱសថ
- បានឃើញប្រកាសលេខ៤១៤ ប្រក.កសក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ ស្ដីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសនៃការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំ លក់រាយ និងការដឹកជញ្ជូនបសុឱសថ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

### ប្រការ១ .-

ប្រកាសនេះមានគោលបំណងកំណត់នូវនីតិវិធីនៃការគ្រប់គ្រងបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទដែលធ្វើពាណិជ្ជកម្ម ធ្វើការផលិត និងធ្វើការលាយផ្សំ សំដៅធានានូវគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាព ដើម្បីការពារសុខភាពសត្វ សុខមាលភាពសត្វ សុខភាពមនុស្ស ផលប្រយោជន៍អ្នកប្រើប្រាស់ និងរួមចំណែកការពារបរិស្ថាន។

### ប្រការ២ .-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់សកម្មភាពដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទដែលធ្វើពាណិជ្ជកម្ម ធ្វើការផលិត និងធ្វើការលាយផ្សំនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## នីតិវិធីនៃការគ្រប់គ្រងបសុឱសថ និងវត្ថុធាតុជីវៈបសុព្យាបាល ដែលធ្វើពាណិជ្ជកម្ម ធ្វើការផលិត និងធ្វើការលាយផ្សំ

### ផ្នែកទី១
### ការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូន

**ប្រការ៣ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងធ្វើការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូនបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវអនុវត្តទៅតាមប្រកាសលេខ៤១៤ ប្រក.កសក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ ២០១៩ ស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសនៃការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូនបសុឱសថ។

### ផ្នែកទី២
### ការបោះពុម្ពផ្សាយ និងការផ្សាយពាណិជ្ជកម្ម

**ប្រការ៤ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងធ្វើការបោះពុម្ពផ្សាយ ឬផ្សាយពាណិជ្ជកម្មបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវដាក់ពាក្យស្នើសុំការយល់ព្រមជាមុននូវការបោះពុម្ពផ្សាយ និងការផ្សាយពាណិជ្ជកម្មលើប្រភេទបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុនោះ ដោយអនុលោមតាមបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។

អត្ថបទបោះពុម្ពផ្សាយ អត្ថបទផ្សព្វផ្សាយ រូបភាពសោតទស្សន៍ បទបង្ហាញ មេរៀនណែនាំបច្ចេកទេស សម្រាប់សិក្ខាសាលាផ្សព្វផ្សាយ ឯកសារបច្ចេកទេសសម្រាប់ពិសោធន៍បង្ហាញ ឬឯកសារផ្សេងទៀតសម្រាប់ការផ្សាយពាណិជ្ជកម្មបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវមានការយល់ព្រមជាមុនពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ប្រការ៥ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវដាក់ពាក្យស្នើសុំធ្វើការបោះពុម្ពផ្សាយ ឬការផ្សាយពាណិជ្ជកម្មបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ នៅអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរយៈពេលយ៉ាងតិច៣០(សាមសិប)ថ្ងៃ នៅមុនកាលបរិច្ឆេទអនុវត្តការផ្សព្វផ្សាយ ឬការផ្សាយពាណិជ្ជកម្ម។

ពាក្យស្នើសុំធ្វើការបោះពុម្ពផ្សាយ ឬការផ្សាយពាណិជ្ជកម្មបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវភ្ជាប់ជាមួយនូវផែនការកម្មវិធីផ្សព្វផ្សាយប្រចាំឆ្នាំរបស់អ្នកស្នើសុំដែលបញ្ជាក់នូវកាលបរិច្ឆេទ និងទីកន្លែងដែលត្រូវធ្វើការផ្សព្វផ្សាយ ការផ្សាយពាណិជ្ជកម្ម សិក្ខាសាលា ឬការធ្វើពិសោធន៍បង្ហាញ ដោយរួមជាមួយអត្ថបទ ឬឯកសារបច្ចេកទេស ដែលត្រូវប្រើប្រាស់ក្នុងការផ្សព្វផ្សាយ ដើម្បីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ធ្វើការពិនិត្យ សិក្សា ឬធ្វើការកែតម្រូវតាមការចាំបាច់ ស្របតាមលក្ខខណ្ឌតម្រូវបច្ចេកទេស និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ៦ .-**

អត្ថបទបោះពុម្ពផ្សាយ ឬអត្ថបទផ្សាយពាណិជ្ជកម្មបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ចាំបាច់ត្រូវមាន៖

១-ខ្លឹមសារបច្ចេកទេសស្របតាមគោលការណ៍ណែនាំដែលកំណត់ដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

២-ភាពអនុលោមតាមព័ត៌មាន ឬទិន្នន័យដែលកំណត់ក្នុងស្លាកសញ្ញាព័ត៌មាន ឬតាមឯកសារបច្ចេកទេសនៃផលិតផលបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដែលបានភ្ជាប់ និងបានអះអាងនៅក្នុងពេលធ្វើការចុះបញ្ជី។

៣-បរិយាយឲ្យមាននិទ្ទេសជាអប្បបរមាដូចខាងក្រោម៖

- អត្តសញ្ញាណប្រភេទបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ រួមមានឈ្មោះពាណិជ្ជកម្ម ឈ្មោះទូទៅ ពាណិជ្ជសញ្ញា និងទម្រង់រូបសាស្ត្រពាក់ព័ន្ធ
- អត្តសញ្ញាណក្រុមហ៊ុនកាន់កាប់បញ្ជិកា លេខបញ្ជិកា ប្រទេស និងក្រុមហ៊ុនប្រភពដើមនៃការផលិត ការលាយផ្សំ ការនាំចូល ការនាំចេញ ការផ្គត់ផ្គង់ចែកចាយ ឬការវេចខ្ចប់ជាថ្មី
- របៀបប្រើប្រាស់ផលិតផលគ្រប់ប្រភេទដែលកំពុងយកមកផ្សព្វផ្សាយនេះ
- គុណភាព ប្រសិទ្ធភាព និងសុវត្ថិភាព របស់ផលិតផលបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ
- ណែនាំអតិថិជនឲ្យអានសេចក្ដីណែនាំនៅក្នុងស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរនៅលើសំបកវេចខ្ចប់ មុននឹងធ្វើការប្រើប្រាស់។

**ប្រការ៧ .-**

បន្ទាប់ពីបានទទួលសេចក្ដីយល់ព្រមលើអត្ថបទបោះពុម្ពផ្សាយ និងអត្ថបទផ្សាយពាណិជ្ជកម្មបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទរួចហើយ រូបវន្តបុគ្គល ឬនីតិបុគ្គលនោះមានសិទ្ធិធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ និងអនុវត្តកម្មវិធីផ្សព្វផ្សាយ ឬការផ្សាយពាណិជ្ជកម្មផលិតផលបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទរបស់ខ្លួននៅតាមរាជធានី ខេត្ត ដោយត្រូវជូនព័ត៌មានដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី ដើម្បីស្នើសុំកិច្ចសហការ។

## ផ្នែកទី៣
## ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ

**ប្រការ៨ .-**

អ្នកផ្គត់ផ្គង់ចែកចាយ ឬអ្នកលក់ដុំ លក់រាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈជាមុន ដើម្បីបំពេញបុរេលក្ខខណ្ឌសម្រាប់ការស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយ ឬលិខិតអនុញ្ញាតលក់ដុំ លក់រាយ។

អ្នកផ្គត់ផ្គង់ចែកចាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវដាក់ពាក្យស្នើសុំឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈសម្រាប់ការធ្វើប្រតិបត្តិការរបស់ខ្លួន នៅអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

អ្នកលក់ដុំ លក់រាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវដាក់ពាក្យស្នើសុំឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ សម្រាប់ការធ្វើប្រតិបត្តិការរបស់ខ្លួននៅការិយាល័យផលិតកម្ម និងបសុព្យាបាលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី។

ការិយាល័យផលិតកម្ម និងបសុព្យាបាលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី ត្រូវដាក់ស្នើសុំមកអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីសហការបើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ និងចេញវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ។

**ប្រការ៩ .-**

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងការិយាល័យផលិតកម្ម និងបសុព្យាបាលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត មានភារកិច្ចក្នុងការរៀបចំលើកគម្រោងបើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ និងផ្តល់សេវាកម្មក្នុងការអនុវត្តកម្មវិធីនៃវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈសម្រាប់ការធ្វើពាណិជ្ជកម្មបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទទៅតាមដែនសមត្ថកិច្ចនីមួយៗ។

## ផ្នែកទី៤
## ការទទួលស្គាល់បុគ្គលិកបច្ចេកទេស

**ប្រការ១០ .-**

បុគ្គលិកបច្ចេកទេសប្រចាំការសម្រាប់គ្រឹះស្ថានដែលធ្វើការនាំចូល នាំចេញ ផលិត លាយផ្សំ វេចខ្ចប់ជាថ្មីនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវមានលក្ខណៈវិនិច្ឆ័យសមស្រប ដើម្បីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ធ្វើការទទួលស្គាល់ដូចខាងក្រោម៖

១- មានសញ្ញាបត្រវេជ្ជសាស្ត្រសត្វ ឬសញ្ញាបត្រសមមូលកម្រិតបរិញ្ញាបត្រឡើងទៅ ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២- មានវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ដែលចេញដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

ក្នុងករណីមានការបញ្ឈប់ ឬផ្លាស់ប្តូរបុគ្គលិកបច្ចេកទេសប្រចាំការ គ្រឹះស្ថានដែលធ្វើការនាំចូល នាំចេញ ផលិត លាយផ្សំ វេចខ្ចប់ជាថ្មីនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវធ្វើសេចក្តីរាយការណ៍ជូនអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីស្នើសុំការទទួលស្គាល់បុគ្គលិកបច្ចេកទេសថ្មីប្រចាំគ្រឹះស្ថាននោះឡើងវិញ។

## ជំពូកទី៥
## វិធានរួម និងកាតព្វកិច្ចអ្នកកាន់លិខិតអនុញ្ញាត

**ប្រការ១១ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលកាន់លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រនៅក្នុងប្រតិបត្តិការពាក់ព័ន្ធនឹងបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវអនុវត្តកាតព្វកិច្ចដូចខាងក្រោម៖

- ត្រូវដាក់តាំងបង្ហាញរាល់លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រសម្រាប់ប្រតិបត្តិការដែលពាក់ព័ន្ធនៅក្នុងគ្រឹះស្ថាន ឬទីកន្លែងអាជីវកម្មរបស់ខ្លួន
- ត្រូវរាយការណ៍ ឬផ្ដល់ព័ត៌មានជូនអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលមានសមត្ថកិច្ចនៅក្នុងមូលដ្ឋានសាមី អំពីគ្រោះថ្នាក់ ឬផលប៉ះពាល់ដែលបង្កដោយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ
- ត្រូវប្រកាសអំពីប្រភេទ យថាប្រភេទ បរិមាណបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទដែលធ្វើអាជីវកម្ម ពាណិជ្ជកម្ម ផលិត ឬធ្វើការលាយផ្សំ និងត្រូវមានកំណត់ត្រាព័ត៌មានចុះក្នុងសៀវភៅកំណត់ត្រាសម្រាប់គ្រប់ប្រតិបត្តិការដែលពាក់ព័ន្ធ
- ត្រូវរក្សាស្ថានភាពអនាម័យនៅក្នុង និងជុំវិញបរិវេណទីកន្លែងផលិតកម្ម និងអាជីវកម្មរបស់ខ្លួន
- ត្រូវអនុវត្តជាប្រចាំនូវកម្មវិធីបណ្ដុះបណ្ដាលស្ដីពីវិធានសុវត្ថិភាពក្នុងគ្រប់ប្រតិបត្តិការដែលពាក់ព័ន្ធ និងបំពាក់ឧបករណ៍ការពារសុវត្ថិភាពដល់បុគ្គលិកប្រតិបត្តិការដោយផ្ទាល់
- ត្រូវកំណត់ និងអនុវត្តបទដ្ឋានបច្ចេកទេសសម្រាប់ប្រើប្រាស់ និងថែទាំឧបករណ៍ដែលប្រើប្រាស់ជាមួយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ និងឧបករណ៍ការពារសុវត្ថិភាព
- ត្រូវអនុវត្តជាប្រចាំនូវកម្មវិធីត្រួតពិនិត្យ និងថែទាំសុខភាពដល់បុគ្គលិកប្រតិបត្តិការផ្ទាល់ជាមួយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ
- ក្នុងករណីដែលមិនបានបំពេញតាមការតម្រូវបមាណីយឬតាមបទដ្ឋានបច្ចេកទេសដែលបានកំណត់ ឬមានហានិភ័យប៉ះពាល់ដល់សុខភាពសត្វ មនុស្ស និងបរិស្ថាន ត្រូវប្រមូលបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ មករក្សាទុក ដើម្បីទប់ស្កាត់ហានិភ័យតាមការចាំបាច់ និងទទួលខុសត្រូវលើរាល់ការចំណាយទាំងនោះ
- ត្រូវបំពេញកាតព្វកិច្ចផ្សេងទៀតដែលមានចែងក្នុងបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់ស្ដីពីសុខភាពសត្វ និងផលិតកម្មសត្វ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។

**ប្រការ១២ .-**

ក្រុមហ៊ុនដែលធ្វើប្រតិបត្តិការនាំចូល នាំចេញ ផលិត លាយផ្សំ វេចខ្ចប់ជាថ្មី ធ្វើសន្និធិ ឬធ្វើការផ្គត់ផ្គង់ចែកចាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់តាំងបង្ហាញនៅក្នុងគ្រឹះស្ថានរបស់ខ្លួននូវលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រដែលពាក់ព័ន្ធ និងត្រូវតម្កល់ឯកសារវិញ្ញាបនបត្របញ្ជាក់បញ្ជិកាប្រភេទបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទដែលកំពុងធ្វើប្រតិបត្តិការពាណិជ្ជកម្ម។

អ្នកលក់ដុំ លក់រាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទនៅក្នុងដែនរាជធានី ខេត្ត ត្រូវដាក់តាំងបង្ហាញក្នុងកន្លែងតាំងលក់របស់ខ្លួននូវលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រដែលពាក់ព័ន្ធ និងត្រូវតម្កល់ឯកសារវិញ្ញាបនបត្រចុះបញ្ជីបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដែលមានបញ្ជាក់លេខបញ្ជិកា។

## ផ្នែកទី៦
## សៀវភៅកំណត់ត្រា

**ប្រការ១៣ .-**

គ្រប់គ្រឹះស្ថានដែលធ្វើប្រតិបត្តិការពាក់ព័ន្ធបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវមានសៀវភៅកំណត់ត្រាលើប្រតិបត្តិការនីមួយៗ ដោយត្រូវអនុវត្តតាមគោលការណ៍ណែនាំស្តីពីការដាក់ឲ្យប្រើប្រាស់ និងអនុវត្តសៀវភៅកំណត់ត្រាសម្រាប់គ្រប់ប្រតិបត្តិការដែលពាក់ព័ន្ធនឹងបសុឱសថ និងចំណីសត្វរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលកំណត់ដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

## ជំពូកទី៣
## ភាគពួកិច្ចបង់កម្រៃសេវាសាធារណៈ

**ប្រការ១៤ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ការទទួលស្គាល់បុគ្គលិកបច្ចេកទេសប្រចាំគ្រឹះស្ថាន និងការបោះពុម្ពផ្សព្វផ្សាយពាណិជ្ជកម្មបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ មានកាតព្វកិច្ចបង់កម្រៃសេវាសាធារណៈចូលថវិកាជាតិដោយអនុលោមតាមប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ១៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៦ .-**

អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៥ កើត ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ១០ ឆ្នាំ២០២០

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ